# កម្មវិធីស្វ័យសម្រេច

**ដំណាក់កាលឆ្លោះទៅអន្តរកាល**

*រយៈពេលធម្មតាខុសគ្នាទៅតាមតម្រូវការរបស់អ្នកចូលរួម

រយៈពេលធម្មតា

**30-90 ថ្ងៃ ដំបូង**

### 1 កម្មវិធីតម្រង់ទិស

ចុះឈ្មោះសម្រាប់កម្មវិធីតម្រង់ទិស SDP ។ ជូនដំណឹងទៅអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ប្រសិនបើអ្នកចាប់អារម្មណ៍ចូលរួម។

### 2 អ្នកសម្របសម្រួលឯករាជ្យ *(IF)* * ជាជម្រើស

បើចង់បាន សូមទាក់ទងមកអ្នកសម្របសម្រួលឯករាជ្យ ដើម្បីជួយអ្នកបង្កើតផែនការថែទាំបុគ្គល (PCP)។ នេះត្រូវបានឧបត្ថម្ភថវិកាដោយមជ្ឈមណ្ឌលប្រចាំតំបន់។

### 3 សេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុ *(FMS)*

ចាប់ផ្តើមស្វែងរក FMS ហើយសួរអំពីគំរូ FMS របស់ពួកគេ។

**30-90 ថ្ងៃ បន្ទាប់**

### 4 កិច្ចប្រជុំមុនធ្វើផែនការ

រៀបចំពេលកិច្ចប្រជុំមុនធ្វើផែនការមួយជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ដើម្បីពិនិត្យមើលរបាយការណ៍ PCP ឡើងវិញ (បើមាន), ពិនិត្យមើលពីតម្រូវការនានា ហើយចាប់ផ្តើមធ្វើផែនការសម្រាប់ដំណាក់កាលបន្ទាប់នៅក្នុង SDP ។

### 5 ថវិការបស់ *SDP*

អ្នកសម្របសម្រួលសេវាកម្មរបស់អ្នកនឹងបង្កើតថវិការបស់ SDP ដោយផ្អែកលើសេវាកម្មដែលបានវាយតម្លៃ និងតម្រូវការទាំងឡាយដែលមិនបានឆ្លើយតប។ ពួកគេនឹងផ្តល់ឲ្យអ្នកនូវថវិកាដែលមានការបញ្ជាក់មួយច្បាប់។

**30 ថ្ងៃ ចុងក្រោយ**

### 6 ផែនការចំណាយ

ប្រសិនបើអ្នកយល់ស្របជាមួយថវិកា អ្នកអាចបន្តជាមួយនឹងដំណើរការបង្កើតផែនការចំណាយមួយ ហើយចែករំលែកមួយច្បាប់ជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នក។

### 7 ផែនការចំណាយរបស់មជ្ឈមណ្ឌល *Harbor*

មជ្ឈមណ្ឌល Harbor នឹងពិនិត្យមើលផែនការចំណាយរបស់អ្នក ហើយនឹងផ្តល់ឲ្យអ្នកនូវផែនការចំណាយរបស់មជ្ឈមណ្ឌល Harbor ដែលបានអនុម័តរួច ហើយចុះហត្ថលេខា ប្រសិនបើអ្នកយល់ស្រប។

### 8 ផ្ញើឯកសារទៅជូន *FMS*

មជ្ឈមណ្ឌល Harbor នឹងបំពេញការអនុញ្ញាត ហើយនឹងផ្តល់ការអនុញ្ញាតនោះ ជាមួយនឹងផែនការចំណាយរបស់មជ្ឈមណ្ឌល Harbor ដែលបានអនុម័តរួច ទៅឲ្យ FMS រយៈ 15 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើម (ថ្ងៃទី 1 នៃខែបន្ទាប់)។

### 9 កាលបរិច្ឆេទចាប់ផ្តើម

ឥឡូវនេះ អ្នកកំពុងចាប់ផ្តើម SDP! អ្នកនឹងជួបជាមួយអ្នកសម្របសម្រួលសេវាកម្មរបស់អ្នកដោយផ្ទាល់ ក្នុងរយៈពេលពីរសប្តាហ៍ដំបូង ដើម្បីបញ្ចប់គម្រោងកម្មវិធីបុគ្គល (IPP) និងចុះហត្ថលេខាលើឯកសារ IPP ។

**ស្កេនដើម្បីមើលព័ត៌មាន SDP របស់មជ្ឈមណ្ឌល Harbor**